**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងព័ត៌មាន**
**MINISTRY OF INFORMATION**
លេខ........១០៧...............ព.មសរ

រាជធានីភ្នំពេញ, ថ្ងៃទី១៥......ខែ..កុម្ភៈ ឆ្នាំ២០០៨

# សេចក្តីសម្រេច
## ស្តីពី
## ការចាត់តាំងគណៈកម្មាធិការបណ្តោះអាសន្ន
## នៃសមាគមសង្គហៈមន្ត្រីក្រសួងព័ត៌មាន

- យោងស្មារតី និងការអនុម័ត ជាឯកច្ឆ័ន្ទរបស់សន្និបាត ក្រសួងព័ត៌មាននាថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ លើសេចក្តីព្រាងលក្ខន្តិកៈសមាគមសង្គហៈមន្ត្រីក្រសួងព័ត៌មាន
- យោងតាមការចាំបាច់បន្ទាន់ដើម្បីកិច្ចដំណើរការរបស់ សមាគមសង្គហៈមន្ត្រីក្រសួងព័ត៌មាន

## រដ្ឋមន្ត្រី ក្រសួងព័ត៌មាន
## <u>សម្រេច</u>

**<u>ប្រការ១</u>** : សម្រេចចាត់តាំងគណៈកម្មាធិការបណ្តោះអាសន្ននៃសមាគមសង្គហៈមន្ត្រីក្រសួងព័ត៌មាន ហៅកាត់ " **ស.ស.ម.ក.ព** " ដែលមានសមាសភាពដូចខាងក្រោមនេះ ÷

| | | |
|---|---|---|
| ១- លោក | **លី វ៉ាន់ហុង** | ប្រធាន |
| ២- លោក | **ឈិន យូន** | អនុប្រធាន |
| ៣- លោក | **ឌី សុខណាត** | អនុប្រធាន |
| ៤- លោក | **ជ័យ វុឌ្ឍី** | អនុប្រធាន |
| ៥- លោកស្រី | **សន ម៉ារ៉ាដា** | សមាជិក |
| ៦- លោក | **ទួន ដាញ៉ិល** | សមាជិក |
| ៧- លោក | **ស៊ិន សុខ** | សមាជិក |
| ៨- លោកស្រី | **ជា ផល្លីន** | សមាជិក |
| ៩- លោក | **ផុស សុវណ្ណ** | ហិរញ្ញិក |
| ១០- លោកស្រី | **លឹម មុំ** | ហិរញ្ញិករង |
| ១១- លោក | **ជា សាវុធ** | លេខាធិការ |

| | | |
|---|---|---|
| ១២- លោក | **នុត ឈឿង** | លេខាធិការរង |
| ១៣- លោក | **កង សុវណ្ណ** | សមាជិកទំនាក់ទំនងការងារទូទៅ |
| ១៤- លោក | **ប៉ុក ហាក់** | សមាជិកទំនាក់ទំនងការងារទូទៅ |
| ១៥- លោក | **ពេញ យ៉ាត** | សមាជិកសម្របសម្រួល មន្ទីរព័ត៌មាន ខេត្ត-ក្រុង |

**ប្រការ២ :** គណៈកម្មាធិការបណ្ដោះអាសន្ន នៃសមាគមសង្គហៈមន្ត្រីក្រសួងព័ត៌មាន ដូចមានចែងក្នុងប្រការ ១ មានភារកិច្ច រៀបចំការងារសមាគមសង្គហៈមន្ត្រីក្រសួងព័ត៌មានឱ្យដំណើរការសមស្របតាម លក្ខន្តិកៈរបស់សមាគម ចំពោះមុខ គឺ÷

ក/- ធ្វើនីត្យានុកូលកម្ម អំពីការបង្កើតសមាគម

ខ/- រៀបចំទម្រង់បែបបទ នៃការចូលសមាជិក

(ទាំងសមាជិកកិត្តិយស ទាំងសមាជិកសកម្ម និងបែបបទ នៃការបង់ភាគទាននិងការឧបត្ថម្ភ)

គ/- អំពាវនាវរកអំណោយសប្បុរសធម៌ ពីសមាជិកកិត្តិយស និងសប្បុរសជននានា

ឃ/- បែងចែកភារកិច្ច ការងារឱ្យបានច្បាស់លាស់ ក្នុងជួរគណៈកម្មាធិការ

ង/- រៀបចំរចនាសម្ព័ន្ធ អនុគណៈកម្មការ នៅតាម ខេត្ត-ក្រុង

ច/- ពិនិត្យលទ្ធភាព និងសុំការអនុញ្ញាតរៀបចំទីតាំងស្នាក់ការសម្រាប់កិច្ចដំណើរការរបស់សមាគម

**ប្រការ៣ :** គណៈកម្មាធិការបណ្ដោះអាសន្នត្រូវរៀបចំមហាសន្និបាតរបស់ខ្លួន ដើម្បីរៀបចំគណៈកម្មាធិការពេញសិទ្ធិរបស់សមាគម ក្នុងរយៈពេល ១ឆ្នាំ។ ក្នុងករណីពុំទាន់មានលទ្ធភាពរៀបចំមហាសន្និបាតបាន គណៈកម្មាធិការបណ្ដោះអាសន្ន អាចពន្យារពេលបានត្រឹមតែ ១ឆ្នាំ និងតែម្ដងគត់។

**ប្រការ៤ :** សមាជិក-សមាជិកាគណៈកម្មាធិការបណ្ដោះអាសន្ន នៃ **ស.ស.ម.ក.ព** មានភារកិច្ចអនុវត្តតាមសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាពស្របតាម លក្ខន្តិកៈសមាគម បន្ថែមលើមុខងារបច្ចុប្បន្ននៅក្នុងស្ថាប័នរៀងៗខ្លួន។

**ចម្លងជូន**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានទាំង ៥ ចំណុះក្រសួងព័ត៌មាន
- មន្ទីរព័ត៌មាន ខេត្ត-ក្រុង
- ឯកសារ - កាលប្បវត្តិ

**រដ្ឋមន្ត្រី**

ក្រសួងព័ត៌មាន

ខៀវ កាញារីទ្ធ